**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

Ministry of Environment

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខ : ០៨៩ សជណ ប.ស្ត

**សូមជម្រាបជូន**

**ឯកឧត្តម ប្រធានយន្តការប្រតិកម្មរហ័ស ទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ** : ករណីការចុះផ្សាយព័ត៌មានរបស់កាសែតរស្មីកម្ពុជាលេខ ១៥១៤ ឆ្នាំទី ១៨ ចុះថ្ងៃទី ៣១-០១ ខែមករា-កុម្ភៈ ឆ្នាំ ២០១០ ក្រោមចំណងជើងថា "សំណុំរឿងសន្តិសុខក្រុមហ៊ុន យិះចៀ វាយជាន់កប្រជាពលរដ្ឋ ៤ នាក់ ឱ្យរបួសទៅដល់តុលាការ" និងករណី មន្ត្រីបរិស្ថានឧទ្យានជាតិ"**ព្រះសីហនុ-រាម**" អាចរកប្រាក់ចំណូលបាន ១៥០០០ ដុល្លារក្នុងមួយខែៗ ពីការរកស៊ីដឹកភ្ញៀវ ។

**យោង** : - អត្ថបទសារព័ត៌មានរបស់កាសែតរស្មីកម្ពុជា លេខ១៥១៤ ឆ្នាំទី ១៨ ចុះថ្ងៃទី ៣១-០១ ខែមករា-កុម្ភៈ ឆ្នាំ ២០១០

- លិខិតលេខ០៨/១០ ឧពន.អកធ.បស្ត ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់នាយកឧទ្យានជាតិ"**ព្រះសីហនុ-រាម**"
- លិខិតលេខ០៩/១០ ឧពន.អកធ.បស្ត ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់នាយកឧទ្យានជាតិ"**ព្រះសីហនុ-រាម**"។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា: យោងអត្ថបទកាសែតរស្មីកម្ពុជាលេខ ១៥១៤ ឆ្នាំទី ១៨ ចុះថ្ងៃទី ៣១-០១ ខែមករា-កុម្ភៈ ឆ្នាំ ២០១០ ក្រោមចំណងជើងថា " សំណុំរឿងសន្តិសុខក្រុមហ៊ុន យិះចៀ វាយជាន់កប្រជាពលរដ្ឋ ៤ នាក់ ឱ្យរបួសទៅដល់តុលាការ " ក្រសួងបរិស្ថានសូមអនុញ្ញាតធ្វើការបំភ្លឺដូចតទៅ រាជរដ្ឋាភិបាលកម្ពុជាបានជូនដំណឹងលេខ ១៧០១ សជណ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ អនុញ្ញាតឱ្យក្រុមហ៊ុនយិះចៀ ធ្វើការសាងសង់ផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៤ រហូតដល់ទីតាំងវិនិយោគ ។ ដោយសារផ្លូវនេះត្រូវកាត់តាមទីតាំងភូមិករស់នៅរបស់ប្រជាជន ក្រុមហ៊ុនធ្វើការចរចារទូទាត់នយោបាយជាបណ្តើរៗ នៅសល់តែពីរគ្រួសារដែលទាមទារហួសហេតុពេក ទើបក្រុមហ៊ុនសម្រេចធ្វើការឈូសឆាយជាបណ្តើរៗ នូវចំណុចដែលបានទូទាត់គោលនយោបាយបានរួច នៅពេលដែលគ្រឿងចក្រ ឈូសឆាយមកដល់ជិតទីតាំងរបស់គ្រួសារទាំងពីរខាងលើ ឈ្មោះ **ចុងប៉ាង** (ភេទស្រី) បានគៀងគរមនុស្សមួយចំនួន ដើម្បីរារាំងការឈូសផ្លូវនេះ ។ ឈ្មោះចុងប៉ាងនេះបានមកឈររាំងមុខគ្រឿងចក្រ ដោយខ្លាចមានការគ្រោះថ្នាក់ទើបបុគ្គលិកក្រុមហ៊ុនធ្វើការរារាំង បន្ទាប់មកឈ្មោះចុងប៉ាងបានស្រែកហៅក្មេងទំនើងមួយក្រុមឱ្យមកជួយរារាំង ស្រាប់តែក្មេងទាំងនោះស្ទុះចូលមក ធាក់តប់លើបុគ្គលិករបស់ក្រុមហ៊ុន។ ការប្រតាយប្រតប់នេះបានធ្វើឱ្យមានរបួសខាងភាគីចុងប៉ាងនេះម្នាក់តែពុំមានស្លាកស្នាមអ្វីធំដុំទេ ។ ឈ្មោះចុងប៉ាងនេះបានធ្វើការសម្របសម្រួលជាមួយក្រុមហ៊ុន

រួចហើយមិន មានទំនាស់អ្វីទៀតទេ ។ លើកលែងតែអ្នកដែលរងរបួស តែមិនមែនជាម្ចាស់ដី បានដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីឆ្លៀតឱកាសទាមទារសំណងពីក្រុមហ៊ុន ។ ដោយឡែកម្ចាស់ដីម្នាក់ទៀត ដែលនៅភ្នំពេញមិនមានការតវ៉ាអ្វីទេ ដែលខុសពីព័ត៌មានដែលកាសែតរស្មីកម្ពុជាបានចុះផ្សាយទាំងស្រុង ថាមានអ្នករបួសដេករណ្តូករណែលនោះ ។

ម៉្យាងទៀតកាសែតលេខដដែលនេះបានចុះផ្សាយអត្ថបទមានចំណងជើងថា មន្ត្រីបរិស្ថានឧទ្យានជាតិ **“ព្រះសីហនុ-រាម”** អាចរកប្រាក់ចំណូលបាន ១៥០០០ដុល្លារក្នុងមួយខែៗ ពីការរកស៊ីដឹកភ្ញៀវ ក្រសួងបរិស្ថានសូមអនុញ្ញាតធ្វើការបំភ្លឺជូនជ្រាបថា ជាទូទៅភ្ញៀវទេសចរណ៍ដែលមកកំសាន្តនៅក្នុងឧទ្យានជាតិ**“ព្រះសីហនុ-រាម”** មានតែបួនខែប៉ុណ្ណោះ គឺខែ វិច្ឆិកា ធ្នូ មករា និងកុម្ភៈ ហើយជាមធ្យមមានភ្ញៀវពី ៣ ទៅ ៥ ទូក ហើយក្នុងមួយទូកមានមនុស្សពី ៣ ទៅ ៩ នាក់។ ការដឹកភ្ញៀវនេះ ក៏បានប្រើប្រាស់ទូកជួលពីប្រជាសហគមន៍ដែលរស់នៅក្បែរៗនោះផងដែរ ដោយគ្រាន់តែទទួលបានសេវានាំភ្ញៀវប៉ុណ្ណោះ ។ ដូច្នេះអ្វីដែលកាសែតរស្មីកម្ពុជា បានចុះផ្សាយនោះ គឺជាព័ត៌មានមិនពិតនិងដើម្បីផលប្រយោជន៍បុគ្គលដែលចុះផ្សាយតែប៉ុណ្ណោះ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាបតាមការគួរ ។
សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**
បណ្ឌិត.ជីវវិទ្យា

<u>ចម្លងជូន</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងព័ត៌មាន
-សាលាខេត្តព្រះសីហនុ
-អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
-មន្ទីរបរិស្ថានខេត្តព្រះសីហនុ
-ឯកសារ-កាលប្បវត្តិ